រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៧

# សេចក្តីថ្លែងការណ៍ ស្តីអំពី
# ពង្រឹងភាពត្រឹមត្រូវតាមច្បាប់ជាតិ និងអន្តរជាតិ( Legitimacy )
# នៃដំណើរការបោះឆ្នោតបែបប្រជាធិបតេយ្យសេរី និងយុត្តិធម៌
# និងការគោរពសម្លេងឆន្ទៈរបស់ម្ចាស់ឆ្នោត

សមាគម អង្គការសង្គមស៊ីវិលមិនមែនរដ្ឋាភិបាលនៅកម្ពុជាដូចមានឈ្មោះខាងក្រោមនេះ មានការព្រួយបារម្ភខ្លាំង ចំពោះការប្តឹងដើម្បីរំលាយគណបក្សសង្គ្រោះជាតិជាគណបក្សប្រជែង និងចំពោះការអនុម័តដោយតំណាងរាស្រ្តតែឯកបក្សនៃគណបក្សដឹកនាំរដ្ឋាភិបាល លើការកែប្រែរូបមន្តថ្មីនៃការបែងចែកអាសនៈតំណាងរាស្រ្ត សមាជិកព្រឹទ្ធសភា ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាឃុំសង្កាត់នៃគណបក្សត្រូវរំលាយ ដែលមានចែងក្នុងសេចក្តីស្នើវិសោធនកម្មច្បាប់ដោយតំណាងរាស្រ្តមកពីគណបក្សដឹកនាំរដ្ឋាភិបាលគណបក្សប្រជាជនកម្ពុជា។ សមាគម អង្គការសង្គមស៊ីវិលមិនមែនរដ្ឋាភិបាលយល់ឃើញថា ជាយថាហេតុការរំលាយគណបក្សប្រជែងនេះ រហូតមិនអាចចូលរួមប្រកួតការបោះឆ្នោតនឹងនាំឲ្យមានបញ្ហានៃភាពត្រឹមត្រូវតាមច្បាប់ជាតិ និងអន្តរជាតិនៃការបោះឆ្នោតឆ្នាំ២០១៨ខាងមុខនេះ។ ម្យ៉ាងទៀត ការអនុវត្តន៍រូបមន្តថ្មីដើម្បីបែងចែងអាសនៈនេះ នឹងធ្វើឲ្យប៉ះពាល់ជាអវិជ្ជមាន និងអយុត្តិធម៌ធ្ងន់ធ្ងរចំពោះសម្លេងម្ចាស់ឆ្នោត តំណាងឆន្ទៈម្ចាស់ឆ្នោតដែលមិនឆ្លុះបញ្ចាំងសមាមាត្រសន្លឹកឆ្នោតនៃភាពជាតំណាងរាស្រ្ត។

ករណីការរំលាយ និងការបែងចែកអាសនៈនៃគណបក្សសង្គ្រោះជាតិបែបនេះ គឺមិនគោរពសម្លេងឆន្ទៈប្រជាពលរដ្ឋប្រមាណ ០៣លាននាក់ដែលបានបោះឆ្នោតគាំទ្រគណបក្សនេះ។ ក្នុងរដ្ឋធម្មនុញ្ញជំពូក៤ ប្រជាពលរដ្ឋជាម្ចាស់វាសនានៃប្រទេសខ្លួន និងអំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ រាជរដ្ឋាភិបាលកម្ពុជាអនុវត្តនយោបាយបង្រួបបង្រួមជាតិ ដើម្បីការពារឯកភាពជាតិ។ ច្បាប់សិទ្ធិមនុស្សអន្តរជាតិ សេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក៏បញ្ជាក់ថា ឆន្ទៈរបស់ប្រជាពលរដ្ឋត្រូវសម្តែងចេញតាមរយៈការបោះឆ្នោត ហើយឆន្ទៈរបស់ប្រជាពលរដ្ឋជាមូលដ្ឋាននៃអំណាច។

ការរំលាយគណបក្ស នាំមកនូវការរំលាយតំណាងរាស្រ្តរបស់ម្ចាស់ឆ្នោត ដែលរដ្ឋធម្មនុញ្ញកម្ពុជាមាត្រា៧៧បានហាមអនុវត្ត ឬទុកជាមោឃៈនូវអាណត្តិអាជ្ញាបញ្ជាទាំងឡាយចំពោះតំណាងរាស្រ្ត។ ម្យ៉ាងទៀត មាត្រា៧៦នៃរដ្ឋធម្មនុញ្ញបញ្ជាក់ថា តំណាងរាស្រ្តត្រូវបានជ្រើសតាំងដោយការបោះឆ្នោត។ នោះនាំឲ្យកើតមានចំណោទបញ្ហានៃភាពត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ដែលតំណាងរាស្រ្តនៃគណបក្សគ្មានអាសនៈក្នុងសភា ត្រូវបានជ្រើសតាំងចេញពីការរំលាយនៃគណបក្សដែលបានអាសនៈសភាទៅវិញ។

ការកែប្រែច្បាប់ទាក់ទិននឹងការបោះឆ្នោតបែបប្រជាធិបតេយ្យ សេរីពហុបក្ស តម្លាភាព និងសុចរិតភាព ត្រូវមានការចូលរួមពិភាក្សាជាមួយគណបក្សនយោបាយនានា និងការអនុម័ត យ៉ាងហោចពីគណបក្សដឹកនាំរដ្ឋាភិបាល និងគណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមដឹកនាំរដ្ឋាភិបាល ដូចមានចែងក្នុងជំពូក៥នៃរដ្ឋធម្មនុញ្ញ និង

ការអនុវត្តន៍កន្លងមក។ សមាគម អង្គការសង្គមស៊ីវិលមិនមែនរដ្ឋាភិបាលនៅកម្ពុជានឹងជួបការលំបាកក្នុងការសង្កេតការណ៍ និងការវាយតម្លៃថា ការបោះឆ្នោតមានភាពត្រឹមត្រូវតាមច្បាប់ ដោយសេរី និងយុត្តិធម៌មួយ ដែលគ្មានការចូលរួមរបស់គណបក្សប្រជែងសំខាន់ ដោយសារការរំលាយជាមួយនឹងការចោទប្រកាន់មេដឹកនាំរបស់គណបក្សបែបនេះ។

ការរំលាយគណបក្សប្រកួតប្រជែងការបោះឆ្នោត និងការអនុវត្តន៍នៃការបែងចែងអាសនៈតាមរូបមន្តថ្មីនៃការធ្វើវិសោធនកម្មច្បាប់នឹងនាំឲ្យបាត់បង់ការប្រកួតប្រជែងការបោះឆ្នោត ដោយភាពត្រឹមត្រូវតាមច្បាប់ជាតិ និងអន្តរជាតិ និងយុត្តិធម៌ ហើយក៏នឹងនាំឲ្យធ្លាក់ចុះខ្លាំងនៃដំណើរការប្រជាធិបតេយ្យជាមួយគុណភាពពហុបក្ស នៅកម្ពុជា។

**សមាគម និងអង្គការសង្គមស៊ីវិលគាំទ្រសេចក្តីថ្លែងការណ៍៖**

1. គណៈកម្មាធិការ ដើម្បីការបោះឆ្នោត ដោយសេរី និងយុត្តិធម៌នៅកម្ពុជា **(COMFREL)**
2. គណៈកម្មការអព្យាក្រឹត្យ និងយុត្តិធម៌ ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា (**NICFEC**)
3. សមាគមធាងត្នោត **(STT)**
4. សម្ព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (**CFSWF**)
5. កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (**YRDP**)
6. បណ្តាញកសាងសន្តិភាពសហគមន៍ **(CPN)**
7. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (**CENTRAL**)
8. មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព **(PDP)**
9. អង្គការស្ម័គ្រចិត្តដើម្បីសង្គម **(CVS)**
10. សម្ព័ន្ធសហគមន៍កសិករកម្ពុជា **(CCFC)**
11. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ **(CCIM)**
12. ក្រុមការងារពិសេសសិទ្ធិលំនៅឋាន (**HRTF**)

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

០១៦ ៨២ ៨២ ១១/០១២ ៨២ ២២ ៧/០៩៣ ៥៥៦ ៦៤៣/០១១ ៥៣ ៥៣ ៥៤/០៧០ ៤០០ ១៣១